**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ១១០៨/២៤ ក.ប/ខ.ល

# សារលិខិតអបអរសាទរ

# ទិវាសន្តិភាពនៅកម្ពុជា

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវអំណរសាទរយ៉ាងពេញទំហឹងចំពោះ "ទិវាសន្តិភាពនៅកម្ពុជា" ថ្ងៃទី២៩ ខែធ្នូ ដែលជាការរំលឹកដឹងគុណ ចងចាំជានិច្ចនូវគំរូវីរភាពដ៏អង់អាចក្លាហាន និងការធ្វើពលិកម្មគ្រប់បែបយ៉ាងរបស់វីរបុរស និងវីរនារីស្នេហាជាតិ ដែលបានប្រយុទ្ធតស៊ូយ៉ាងស្វិតស្វាញនៅគ្រប់សមរភូមិ រហូតសម្រេចបាននូវការបញ្ចប់ភ្លើងសង្គ្រាមនៅកម្ពុជាជាស្ថាពរ នាំមកនូវការបង្រួបបង្រួមជាតិ ឯកភាពជាតិ និងសុខសន្តិភាពពេញលេញ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមសម្តែងនូវការដឹងគុណ និងគោរពកោតសរសើរដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាឯកអគ្គមគ្គុទ្ទេសក៍ និងជាស្ថាបនិកមួយរូបនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលទទួលបានការគាំទ្រពីប្រជាជន បានវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ នាំមកនូវជ័យជម្នះជាប្រវត្តិសាស្ត្រនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលត្រូវបានប្រជាជនកម្ពុជាប្រសិទ្ធនាមថាជា ថ្ងៃកំណើតទី២របស់ខ្លួន និងបានបញ្ចប់សង្គ្រាមរ៉ាំរ៉ៃ បង្កើតបាននូវសន្តិភាពពេញលេញ មានការឯកភាពជាតិ ឯកភាពទឹកដីទាំងស្រុងតាមរយៈការដាក់ចេញ និងអនុវត្តដោយជោគជ័យនយោបាយឈ្នះ-ឈ្នះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។ លើសពីនេះ សន្តិភាពបានជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនលើគ្រប់វិស័យ និងបានលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខដុមរមនា ព្រមទាំងលើកស្ទួយកិត្តិយសជាតិលើឆាកអន្តរជាតិ។ សន្តិភាពដែលប្រទេសយើងអាចរក្សាបាននេះ ពិតជាមានតម្លៃខ្លាំងណាស់សម្រាប់យើងខ្ញុំ។ ជាក់ស្តែងនាពេលថ្មីៗនេះ កម្ពុជាមានកិត្តិយស **ជាប់ឆ្នោតជាសមាជិកនៃគណៈកម្មាធិការចាត់តាំង នៃគណៈកម្មាធិការកសាងសន្តិភាពអង្គការសហប្រជាជាតិ (អ.ស.ប.) សម្រាប់អាណត្តិ ២០២៥-២០២៦** ក្នុងសម័យប្រជុំពេញអង្គលើកទី៥៤ នៃមហាសន្និបាតអ.ស.ប. កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ នៅទីក្រុងញូវយ៉ក ដែលនេះគឺជាសមិទ្ធផលដ៏សំខាន់មួយ បញ្ជាក់អំពីការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួនរបស់កម្ពុជាចំពោះសន្តិភាពពិភពលោក ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។

យើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញារួមគ្នាបន្តថែរក្សាតម្លៃនៃសន្តិភាពនេះ ឱ្យបានគង់វង្សស្ថិតស្ថេរ ព្រមទាំងបន្តបំផុសស្មារតីដល់ប្រជាជនកម្ពុជាគ្រប់ជំនាន់ ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគតឱ្យយល់ដឹងច្បាស់អំពី "គុណតម្លៃនៃសុខសន្តិភាព" ហើយរួមគ្នាលើកកម្ពស់ "វប្បធម៌សន្តិភាព" នៅកម្ពុជា ពិសេស ការចូលរួមការពារ និងថែរក្សាឱ្យបានជាច់ខាតនូវ "សុខសន្តិភាព" ដែលជាអាយុជីវិតរបស់ជាតិ និងជាគ្រឹះដ៏មានតម្លៃបំផុតសម្រាប់ការអភិវឌ្ឍប្រទេសជាតិ និងភាពសុខសាន្តរបស់ប្រជាជនកម្ពុជាប្រកបដោយចីរភាព និងកិយ្យោភាព។

ថ្ងៃពុធ ១៣រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩